# ខែតុលា ជាកំណត់ខែដើរទៅសាលារៀន

ជូននិងទទួលកូនរបស់អ្នកពីសាលារៀនដោយសុវត្ថិភាព

## ជូនចំពោះមាតាបិតា :



ពេលនេះ ជាកំណត់ពេលប្រចាំឆ្នាំក្នុងការចាប់ផ្តើមរៀបចំគម្រោងការអំពីវិធីជូន និងទទួលកូនរបស់អ្នកពីសាលារៀន។ ចរាចរមុន និង  ក្រោយពេលចេញពីសាលារៀនអាចធ្វើអោយតានតឹងអារម្មណ៍ ជាញឹកញាប់នាំអោយគ្រោះថ្នាក់ដល់កូនរបស់យើង។ តែសូមកុំភ្លេចថាមានជម្រើសផ្សេងៗ ទៀតក្នុងការជូន និងទទួលកូនរបស់អ្នកពីសាលារៀនដែលអាចមានផលប្រយោជន៍គ្រប់ៗ គ្នា។

## ដើរ ឬជិះកង់ទៅសាលារៀន

បើសិនជាអ្នករស់នៅជិតសាលារៀន សូមគិតជ្រើសយកការដើរ ឬជិះកង់ជាមួយកូនអ្នកទៅ សាលារៀន។បើកូនអ្នកវាធំដឹងក្តីគ្រប់គ្រាន់ អនុញ្ញាតអោយវាដើរ ឬជិះកង់ជាមួយមិត្តភ័ក្រវាទៅ សាលារៀន។ សិស្សដែលដើរ ឬជិះកង់ទៅរៀន ពេលមកដល់សាលារៀនវាមានភាពប្រុងប្រយ័ត្ន ហើយប្រុងប្រៀបជាស្រេចដើម្បីរៀនសូត្រ។

## ចតរថយន្ត ពីរបីប្លុកពីសាលារៀន ហើយដើរពីទីនោះទៅ

ការដើរជាមួយនិងកូនអ្នកទៅសាលារៀន កាត់បន្ថយការស្ទះចរាចរនៅជុំជិតសាលារៀន ហើយផ្តល់ឱកាសអោយអ្នកនិងកូនរបស់អ្នកចំណាយពេលវេលាដ៏មានតម្លៃជាមួយគ្នា ព្រមទាំងផ្តល់សកម្មភាពកាយវប្បកម្មខ្លះៗ ដល់អ្នកទាំងពីររូប។

## ជិះឡានចូលរួមគ្នា ជាមួយនិងអ្នកជិតខាង

រកក្រុមគ្រួសារផ្សេងទៀត នៅតំបន់ជិតខាងរបស់អ្នក ដែលចាប់អារម្មណ៍ក្នុងការដាក់វេនបើកបរជូនកូនទៅ និងទទួលកូនមកពីសាលារៀនវិញ។ ធ្វើបែបនេះ នឹងកាត់បន្ថយការស្ទះចរាចរជុំជិតសាលារៀន ហើយទុកពេលអោយអ្នកធ្វើអ្វីៗផ្សេងៗ ទៀតនៅពេលព្រឹក និងពេលរសៀល។

## រថយន្តសាលារៀន ឬរថយន្តសាធារណៈ

ចុះឈ្មោះកូនអ្នកទៅក្នុងកម្មវិធីរថយន្តសាលារៀន ឬអោយកូនធំៗ ជិះរថយន្តសាធារណៈ ជាវិធីងាយស្រួល និងប្រកបដោយសុវត្ថិភាពសំរាប់កូនអ្នកទៅសាលារៀន ជាពិសេសសិស្សដែលរស់នៅឆ្ងាយដែលពុំអាចដើរ ឬជិះកង់បាន។ សិស្សធំៗ អាចជិះរថយន្តសាធារណៈ ហើយឈប់ពីរបីប្លុកមុនទៅដល់សាលារៀន ហើយដើរពីទីនោះទៅសាលារៀន បើសិនជាតំបន់ជិតខាងនោះប្រកបដោយសុវត្ថិភាព។

## បើកបរដោយសុវត្ថិភាព




បើអ្នកជ្រើសបើកបរជូនកូនអ្នករៀន សូមចាំថាបើកបរដោយយឺតៗ ហើយដោយសុវត្ថិភាពនៅក្នុងបរិវេណសាលារៀន។ ក្មេងៗ ពិតពិបាកនឹងប៉ាន់ស្មានចិត្តវាណាស់ ហើយយើងមើលវាពុំឃើញនៅវាដើរឬជិះកង់ទៅសាលារៀន។ នៅពេលអ្នកដាក់កូននៅសាលារៀន សូមដាក់វានៅម្ខាង ហើយសូមកុំចតរថយន្តទន្ទឹមគ្នា ឬបញ្ឆេះឡានចោល ធ្វើដូច្នេះវាធ្វើអោយស្ទះចរាចរនៅជុំជិតសាលារៀន ហើយធ្វើខ្យល់អាកាសកខ្វក់។

សូមគិតជ្រើសយកជម្រើសណាមួយដូចខាងលើនេះ ក្នុងការជូន និងទទួលកូនអ្នកពីសាលារៀន។ ជម្រើសរបស់អ្នកនិងធ្វើអោយសុខភាព និងសុវត្ថិភាពមានភាពប្រសើរឡើងដល់ជនគ្រប់រូប មានរួមទាំងកូនរបស់អ្នកទៀតផង។

ដោយសេចក្តីរាប់អាន,

www.cawalktoschool.com